# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខៈ ០២៤ គ.ជ.ប.ស.ន.ឈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសសមាសភាពគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ត្រូវការជ្រើសរើសសមាសភាពគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) ចំនួន ៨.៣៤២រូប ជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ឱ្យបម្រើការងារនៅតាមគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ដែលមានមុខតំណែងដូចខាងក្រោម ៖

| | |
|---|---|
| ១- ប្រធានទទួលបន្ទុកដឹកនាំការងាររួម និងការងារហិរញ្ញវត្ថុ | ចំនួន ១ រូប |
| ២- អនុប្រធានជួយធ្វើការប្រធាន និងទទួលបន្ទុកលើការងារប្រតិបត្តិការ និងបច្ចេកទេស | ចំនួន ១ រូប |
| ៣- សមាជិកទទួលបន្ទុកលើការងាររដ្ឋបាល | ចំនួន ១ រូប |
| ៤- សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត | ចំនួន ១ រូប |
| ៥- សមាជិកទទួលបន្ទុក អប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ | ចំនួន ១ រូប ឬ២រូប ឬ៣រូប |

## I- លក្ខខណ្ឌទូទៅនៃបេក្ខជន ៖

- មានសញ្ជាតិខ្មែរ
- មានកិរិយាមារយាទល្អ និងសុចរិតទៀងត្រង់ គោរពច្បាប់ និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងក្រមសីលធម៌មន្ត្រីបោះឆ្នោត
- មានសិទ្ធិបោះឆ្នោត និងមានទីលំនៅក្នុងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- មានសុខភាពល្អ
- មានលទ្ធភាពធ្វើដំណើរក្នុងព្រះរាជាណាចក្រកម្ពុជា ឬក្នុងរាជធានី ខេត្ត ឬក្នុងឃុំ សង្កាត់
- មិនត្រូវជាសហព័ទ្ធ ឬញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ នៅក្នុងគណៈកម្មការតែមួយ
- មិនមែនជាកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ
- មិនមែនជាមន្ត្រីតុលាការក្នុងក្របខណ្ឌការងារ
- មិនមែនជាព្រះសង្ឃ ឬបព្វជិតសាសនា
- មិនមែនជាអភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- មិនមែនជាមេភូមិ អនុប្រធានភូមិ ឬសមាជិកភូមិ
- មិនមែនជាជនដែលតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ

- ប្រធាន អនុប្រធាន និងសមាជិក គឃ.សប ដែលជាសមាជិកគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងមន្ត្រីរាជការក្រោយពីបានទទួលការតែងតាំង ត្រូវលាលែងពីសមាជិកនៃគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងត្រូវដាក់ពាក្យសុំទៅបម្រើការងារក្រៅក្របខណ្ឌដើម រហូតដល់ថ្ងៃចប់ភារកិច្ច
- បេក្ខនារី ឬបេក្ខជន និងបេក្ខនារីដែលជាជនជាតិដើមភាគតិចនៅតំបន់ដែលមានជនជាតិដើមភាគតិចតាមចំនួនសមស្រប និងចំពោះបេក្ខជន និងបេក្ខនារីជាជនមានពិការភាពដែលមានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងមុខតំណែង ត្រូវបានលើកទឹកចិត្ត
- បេក្ខជនអាចដាក់ពាក្យបានតែមួយមុខតំណែង ឬ/និង មួយឃុំ សង្កាត់ តែប៉ុណ្ណោះ។

## II- លក្ខខណ្ឌដោយឡែក ÷

### ១- ប្រធាន គឃ.សប

- មានអាយុយ៉ាងតិច ២២ ឆ្នាំ ឡើងទៅគិតដល់ថ្ងៃតែងតាំង
- មានសញ្ញាបត្រចាប់ពីមធ្យមសិក្សាទុតិយភូមិឡើង ឬសញ្ញាបត្រសមមូល ឬបទពិសោធន៍ការងារសមស្របនឹងមុខតំណែងចាប់ពី ១ឆ្នាំ ឬមានបទពិសោធន៍ខាងការងារបោះឆ្នោតសមស្របនឹងមុខតំណែង ១ដងឡើងទៅ
- មានបទពិសោធន៍ខាងការងារគ្រប់គ្រង និងចាត់ចែងកិច្ចប្រតិបត្តិការ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៤០០.០០០ រៀល
- *មុខតំណែងនេះត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។*

### ២- អនុប្រធាន គឃ.សប

- មានអាយុយ៉ាងតិច ២២ ឆ្នាំ ឡើងទៅគិតដល់ថ្ងៃតែងតាំង
- មានសញ្ញាបត្រចាប់ពីមធ្យមសិក្សាទុតិយភូមិឡើង ឬសញ្ញាបត្រសមមូល ឬបទពិសោធន៍ការងារសមស្របនឹងមុខតំណែងចាប់ពី ១ឆ្នាំ ឬមានបទពិសោធន៍ខាងការងារបោះឆ្នោតសមស្របនឹងមុខតំណែង ១ដងឡើងទៅ
- មានបទពិសោធន៍ក្នុងការងារគ្រប់គ្រង ឬការងារចាត់ចែងកិច្ចប្រតិបត្តិការ មានសមត្ថភាពជួយការងារដល់ប្រធាន និងប្រសិនបើប្រធានអវត្តមានត្រូវជំនួសប្រធាន
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៣៥០.០០០ រៀល
- *មុខតំណែងនេះត្រូវប្រឡងពីរមុខគឺ ១- សរសេរ-QCM ២- សម្ភាសន៍។*

### ៣- សមាជិកទទួលបន្ទុកលើការងាររដ្ឋបាល

- មានអាយុយ៉ាងតិច ២២ ឆ្នាំ ឡើងទៅគិតដល់ថ្ងៃតែងតាំង
- មានសញ្ញាបត្រចាប់ពីមធ្យមសិក្សាទុតិយភូមិឡើង ឬសញ្ញាបត្រសមមូល ឬបទពិសោធន៍ការងារសមស្របនឹងមុខតំណែងចាប់ពី ១ឆ្នាំ ឬមានបទពិសោធន៍ខាងការងារបោះឆ្នោតសមស្របនឹងមុខតំណែង ១ដងឡើងទៅ
- មានបទពិសោធន៍ការងាររដ្ឋបាល
- ចេះប្រើប្រាស់កុំព្យូទ័រច្បាស់លាស់ ព្រមទាំងចេះប្រើប្រាស់ **Internet** និង **Email**
- បេក្ខជនដែលធ្លាប់បម្រើការងារសមាជិក គ.ច.ប ជាការីកុំព្យូទ័រ ត្រូវបានលើកទឹកចិត្ត
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៣០០.០០០ រៀល
- *មុខតំណែងនេះត្រូវប្រឡងបីមុខគឺ ១-QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ២-ធ្វើតេស្តកុំព្យូទ័រ ៣-សម្ភាសន៍។*

### ៤- សមាជិកទទួលបន្ទុកលើការងារសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត

- មានអាយុយ៉ាងតិច ២២ ឆ្នាំ ឡើងទៅគិតដល់ថ្ងៃតែងតាំង
- មានសញ្ញាបត្រចាប់ពីមធ្យមសិក្សាទុតិយភូមិឡើង ឬសញ្ញាបត្រសមមូល ឬបទពិសោធន៍ការងារសមស្របនឹងមុខតំណែងចាប់ពី ១ឆ្នាំ ឬមានបទពិសោធន៍ខាងការងារបោះឆ្នោតសមស្របនឹងមុខតំណែង ១ដងឡើងទៅ
- មានបទពិសោធន៍ការងារច្បាប់ បទពិសោធន៍ការងារសម្របសម្រួល ឬ/និងការងារសន្តិសុខ

- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៣០០.០០០ រៀល
- *មុខតំណែងនេះត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។*

**៥- សមាជិកទទួលបន្ទុកលើការងារអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ:**

- មានអាយុយ៉ាងតិច ២២ ឆ្នាំ ឡើងទៅគិតដល់ថ្ងៃតែងតាំង
- មានសញ្ញាបត្រចាប់ពីមធ្យមសិក្សាទុតិយភូមិឡើង ឬសញ្ញាបត្រសមមូល ឬបទពិសោធន៍ការងារសមស្រប នឹងមុខតំណែងចាប់ពី ១ឆ្នាំ ឬមានបទពិសោធន៍ខាងការងារបោះឆ្នោតសមស្របនឹងមុខតំណែង ១ដង ឡើងទៅ
- មានបទពិសោធន៍ការងារបណ្តុះបណ្តាល និងអប់រំ
- ប្រាក់កម្រៃក្នុងមួយខែទទួលបាន ១.៣០០.០០០ រៀល
- *មុខតំណែងនេះត្រូវប្រឡងពីរមុខគឺ ១-សរសេរ-QCM ២-សម្ភាសន៍។*

## III- វិញ្ញាសាប្រឡង ៖

- ចំណេះដឹងទូទៅទាក់ទងនឹងការបោះឆ្នោត
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

## IV- ភារកិច្ច និងការទទួលខុសត្រូវនៃ គឃ.សប

គឃ.សប ត្រូវមានការទទួលខុសត្រូវក្នុងការរៀបចំ និងចាត់ចែងការបោះឆ្នោតនៅឃុំ សង្កាត់របស់ខ្លួនតាមការប្រគល់សិទ្ធិ និងត្រួតពិនិត្យនីត្យានុកូលភាពដោយ គ.ជ.ប តាមរយៈ គធ.ខប ។ គឃ.សប ត្រូវ ៖

១- អនុវត្តភារកិច្ចដែលច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងលិខិតបទដ្ឋាននានា ដែលបានអនុញ្ញាត ឬតម្រូវឱ្យអនុវត្ត។

២- អនុវត្តភារកិច្ច និងសិទ្ធិដទៃទៀតដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រគល់ឱ្យ។

គឃ.សប មានភារកិច្ច និងការទទួលខុសត្រូវជាក់លាក់ដូចខាងក្រោម ៖

- គោរព និងអនុវត្តច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោត ក្រមសីលធម៌ សម្រាប់មន្ត្រីបោះឆ្នោត និងគោលការណ៍ណែនាំរបស់ គ.ជ.ប
- គោរព និងអនុវត្តផែនការមេ និងប្រតិទិននៃការបោះឆ្នោត
- ចាត់គ្រប់វិធានការចាំបាច់ ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរីត្រឹមត្រូវ និងយុត្តិធម៌ តាមរយៈការបោះឆ្នោតជាសម្ងាត់
- ចូលរួមវគ្គបណ្តុះបណ្តាលដែលរៀបចំដោយ គធ.ខប
- ចាត់វិធានការដើម្បីទប់ស្កាត់ និងដោះស្រាយរាល់ភាពមិនប្រក្រតីក្នុងដំណើរការបោះឆ្នោត
- គ្រប់គ្រងថវិការបស់ខ្លួន និងថែរក្សាសម្ភារឯកសារសម្រាប់ការបោះឆ្នោត
- ដឹកនាំការប្រជុំជាមួយភាគីពាក់ព័ន្ធអំពីការបោះឆ្នោត និងសន្តិសុខបោះឆ្នោតក្នុងឃុំ សង្កាត់
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងចាត់វិធានការការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈក្នុងដំណើរការបោះឆ្នោត
- លើកកម្ពស់ការយល់ដឹងអំពីការបោះឆ្នោតដល់អ្នកបោះឆ្នោត
- ចែកចាយរាល់ឯកសារ និងព័ត៌មានពាក់ព័ន្ធទៅនឹងដំណើរការបោះឆ្នោត
- ផ្សព្វផ្សាយជាសាធារណៈនូវសេចក្តីណែនាំ សេចក្តីជូនដំណឹង និងប្រកាសព័ត៌មានរបស់ គ.ជ.ប និងព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោតក្នុងឃុំ សង្កាត់
- ចាត់ចែងការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត
- អនុវត្តការជ្រើសរើស គ.ក.ប តាមការណែនាំរបស់ គធ.ខប និង គ.ជ.ប
- បណ្តុះបណ្តាល គ.ក.ប តាមកម្មវិធី និងការណែនាំរបស់ គធ.ខប និង គ.ជ.ប
- ទទួល និងបែងចែកសម្ភារ បរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- សហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ លើកយោបល់ជូន គធ.ខប អំពីការកែសម្រួលទីតាំងការិយាល័យបោះឆ្នោត

- បិទផ្សាយបញ្ជីបោះឆ្នោត និងបញ្ជីទីតាំងការិយាល័យបោះឆ្នោត
- អនុវត្តការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ
- គ្រប់គ្រង សម្របសម្រួល និងត្រួតពិនិត្យការឃោសនាបោះឆ្នោត
- ចាត់វិធានការ និងសម្របសម្រួលដើម្បីធានាការប្រើប្រាស់អគារ ឬទីសាធារណៈ ក្នុងការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមគោលការណ៍ស្មើភាព និងសមធម៌ និងតាមលំដាប់មុនក្រោយ
- សហការជាមួយមេឃុំ ចៅសង្កាត់ក្នុងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត
- គ្រប់គ្រងនីតិវិធីបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត
- គ្រប់គ្រងនីតិវិធីរាប់សន្លឹកឆ្នោត និងចាត់ចែងការរាប់សន្លឹកឆ្នោត
- ចាត់ចែងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់
- អនុវត្តនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងពាក់ព័ន្ធនឹងការបោះឆ្នោតក្នុងឃុំ សង្កាត់តាមសមត្ថកិច្ចរបស់ខ្លួន
- រៀបចំ និងប្រគល់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតជូនទៅ គធ.ខប តាមប្រតិទិន
- ប្រមូល និងវេចខ្ចប់សម្ភារ បរិក្ខារ ឯកសារបោះឆ្នោតបញ្ជូនទៅ គធ.ខប តាមការកំណត់
- រាយការណ៍ និងផ្ដល់យោបល់ជូន គធ.ខប អំពីសភាពការណ៍ និងបរិយាកាសក្នុងឃុំ សង្កាត់ដើម្បីធានាឱ្យការបោះឆ្នោតបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌
- អនុវត្តភារកិច្ចដែលច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងលិខិតបទដ្ឋាននានាដែលបានអនុញ្ញាត ឬតម្រូវឱ្យអនុវត្ត
- អនុវត្តភារកិច្ច និងសិទ្ធិដទៃទៀត ដែល គ.ជ.ប និង គធ.ខប ប្រគល់ឱ្យ។

## V- **រយៈពេលបម្រើការងារ**

ចាប់ផ្ដើមចូលបម្រើការងារពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ ដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣។

## VI- **ទំនាក់ទំនងព័ត៌មាន**

សាធារណជនដែលមានបំណងដាក់ពាក្យជាបេក្ខជនតាមមុខតំណែងខាងលើនេះ សូមអញ្ជើញមកទំនាក់ទំនងទទួល និងដាក់ពាក្យនៅរៀងរាល់ម៉ោងធ្វើការនៅតាមទីប្រមូលផ្ដុំ ក្រុង ស្រុក ខណ្ឌ ឬតាមទីកន្លែងដែលកំណត់ដោយ គធ.ខប ។

ពាក្យសុំប្រឡងចូលបម្រើការងារនឹងមានចែកជូនដោយឥតគិតថ្លៃ។

ឃុំ សង្កាត់ដែលត្រូវជ្រើសរើសសមាជិកទទួលបន្ទុកផ្នែកអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ ចំនួន ២រូប មានចំនួន ៧២ ឃុំ សង្កាត់ និងចំនួន ៣រូប មានចំនួន ៥ ឃុំ សង្កាត់ នៃរាជធានី ខេត្តចំនួន ១៤ ដូចមានតារាងឈ្មោះឃុំ សង្កាត់ ជូនភ្ជាប់មកជាមួយ។ បេក្ខជនអាចទាញយកពាក្យសុំប្រឡងចូលបម្រើការងារតាមរយៈគេហទំព័ររបស់ គ.ជ.ប (www.nec.gov.kh) ឬស្កេន QR-Code លើសេចក្ដីជូនដំណឹងផ្សព្វផ្សាយ។

## VII- **កាលបរិច្ឆេទនៃការទទួលពាក្យ និងការប្រឡងសរសេរ-QCM ប្រឡង QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ធ្វើតេស្តកុំព្យូទ័រ និងសម្ភាសន៍**

ការទទួលពាក្យសុំប្រឡងចូលបម្រើការងារនឹងធ្វើនៅតាមទីប្រមូលផ្ដុំ ក្រុង ស្រុក ខណ្ឌ ឬតាមទីកន្លែងដែលកំណត់ដោយ គធ.ខប ៖

- ការចាប់ផ្ដើមចែកពាក្យ និងទទួលពាក្យ ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣ ( វេលាម៉ោង ៧:០០ នាទីព្រឹក )
- ការឈប់ទទួលពាក្យ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៣ ( វេលាម៉ោង ១៧:៣០ នាទីល្ងាច )
- ការបិទផ្សាយបញ្ជីឈ្មោះបេក្ខជនដែលត្រូវប្រឡងចន្លោះពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣ នៅតាមសាលាឃុំ សង្កាត់ នៃរាជធានី ខេត្ត
- ការប្រឡងសរសេរ-QCM ប្រឡង QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ធ្វើតេស្តកុំព្យូទ័រ និងសម្ភាសន៍ មានរយៈពេល ១ថ្ងៃ គឺនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ នៅមណ្ឌលប្រមូលផ្ដុំនៃក្រុង ស្រុក ខណ្ឌ ដែលកំណត់ដោយ គធ.ខប ។

**VIII- ការអនុវត្តតាមបទបញ្ជាផ្ទៃក្នុងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

ក្នុងការចែកពាក្យ ទទួលពាក្យ និងប្រឡង គធ.ខប ត្រូវពិនិត្យសំណុំលិខិតរបស់បេក្ខជន និងត្រូវធ្វើការពិនិត្យ និងជ្រើសរើសយកបេក្ខជនដែលមានលក្ខខណ្ឌល្អជាងគេ ៣រូប សម្រាប់មួយមុខតំណែង ដើម្បីមកប្រឡងសរសេរ-QCM ប្រឡង QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ធ្វើតេស្តកុំព្យូទ័រ និងសម្ភាសន៍។

សំណុំលិខិតរបស់បេក្ខជនមិនត្រូវប្រគល់ជូនវិញទេ។

**IX- លទ្ធផលនៃការប្រឡងសរសេរ-QCM ប្រឡង QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ធ្វើតេស្តកុំព្យូទ័រ និងសម្ភាសន៍**

លទ្ធផលនៃការប្រឡងសរសេរ-QCM ប្រឡង QCM ក្នុងប្រព័ន្ធកុំព្យូទ័រ ធ្វើតេស្តកុំព្យូទ័រ និងសម្ភាសន៍ នឹងបិទផ្សាយនៅតាមសាលាឃុំ សង្កាត់ និងគេហទំព័ររបស់ គ.ជ.ប ។

**<u>បញ្ជាក់បន្ថែម</u>** ÷

- សញ្ញាបត្រ ឬ/និងលិខិតបញ្ជាក់ពីបទពិសោធន៍ការងារត្រូវធ្វើនីត្យានុកូលកម្ម ឬមានការបញ្ជាក់ពីសាមីស្ថាប័ន
- គ្រប់បេក្ខជនត្រូវមានអ្នកធានាដឹងឮយ៉ាងតិចមួយនាក់
- បេក្ខជនទាំងអស់ត្រូវធានាថា ក្រោយពីពេលដែលត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារក្នុងមុខតំណែងណាមួយនោះ ត្រូវសុខចិត្តទទួលយកប្រាក់កម្រៃដូចបានកំណត់ហើយនឹងត្រូវបើកជូនក្រោយពី គ.ជ.ប បានទទួលប្រាក់ពីរតនាគារជាតិ
- យោងតាមមាត្រា២៦ នៃអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចែងថា «... មន្ត្រីរាជការដែលត្រូវបានជ្រើសរើសពីក្រសួង ស្ថាប័ននានា ជាមន្ត្រីជាប់កិច្ចសន្យាបម្រើការងារឱ្យ គ.ជ.ប ត្រូវបានរក្សាបៀវត្ស ប្រាក់បំណាច់ផ្សេងៗ អតីតភាពការងារ សម្រាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍នៅអង្គភាពដើមរបស់ខ្លួនដដែល»
- ការសូក និងទទួលសំណូកគឺជាអំពើខុសច្បាប់ ដែលត្រូវផ្តន្ទាទោសតាមច្បាប់។

ថ្ងៃ ប្រហស្បតិ៍ ៣ រោច ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មីនា ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**